ន.ផ.ប

# ប្រតិទិនចាក់ថ្នាំការពារជំងឺឆ្លងសត្វ គោ-ក្របី ប្រចាំឆ្នាំ



| ប្រភេទថ្នាំការពារជំងឺ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អុតក្តាម | ■ | ■ | ■ | | | | | | | | ■ | ■ |
| សារទឹក | ■ ■ | ■ ■ | ■ ■ | | | | ■ | ■ | ■ | | ■ | ■ |
| ឈាមខ្មៅ | ■ | ■ | ■ | ■ | | | | | | | | |
| បូសខ្យល់ | ■ | | | | | | | | | ■ | ■ | ■ |



## ប្រសិទ្ធភាពនៃថ្នាំការពារ និង របៀបប្រើប្រាស់

១- វ៉ាក់សាំងជំងឺអុតក្តាម បូសខ្យល់ និងឈាមខ្មៅផ្តល់ភាពស៊ាំ ដែលអាចការពារបានក្នុងរយៈពេល ១០-១២ ខែ

២- វ៉ាក់សាំងជំងឺសារទឹក ផ្តល់ភាពស៊ាំ ដែលអាចការពារបានក្នុងរយៈពេល :

- ៦ ខែ ចំពោះវ៉ាក់សាំងប្រភេទរាវ
- ១២ ខែ ចំពោះវ៉ាក់សាំងប្រភេទខាប់

៣- ការចាក់ថ្នាំការពារត្រូវប្រព្រឹត្តទៅក្នុងពីរជំហាន :

ក. ការចាក់វ៉ាក់សាំងជំហានទី ១ ជាការចាក់លើកដំបូង ដែលតំរូវអោយយើងចាក់ពីរដង ចំពោះសត្វមួយក្បាល ដោយមានរយៈពេលចន្លោះពីគ្នា ២-៤អាទិត្យ យ៉ាងយូរបំផុត ។

ខ. ការចាក់វ៉ាក់សាំងជំហានទី ២ ហៅថារំលឹក តម្រូវឱ្យយើងចាក់នៅ ៦ ខែ ទៅ ១២ ខែ បន្ទាប់ពីចាក់លើកដំបូង អាស្រ័យទៅតាមរយៈពេលស្ថេររបស់ភាពស៊ាំនៃថ្នាំការពារនិមួយៗ ។

៤- អនុវត្តន៏ការចាក់វ៉ាក់សាំងបានទាំងអស់គ្នាតាមប្រតិទិននេះគឺនាំមកនូវប្រសិទ្ធិភាពល្អប្រសើរបំផុត ក្នុងការទប់ស្កាត់ និងកំចាត់ជំងឺឆ្លងសត្វ ។

**កំណត់ចំណាំ :** សូមកុំភ្លេចថាការចាក់វ៉ាក់សាំងមួយមុខ គឺការពារជំងឺបានតែមួយមុខប៉ុណ្ណោះ ! មិនមានន័យថា ការចាក់វ៉ាក់សាំងមួយមុខអាចការពារជំងឺឆ្លងបានគ្រប់មុខនោះទេ ! វ៉ាក់សាំងចាប់មានប្រសិទ្ធភាពក្រោយពេលចាក់បាន ១០ ថ្ងៃ ។